**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

សៀវភៅណែនាំ

ស្ដីអំពី

# ការបង្រៀន និងរៀនវិទ្យាសាស្ត្រ តាមបែបរិះរក

## Inquiry-Based Learning

ដើម្បីឲ្យការអនុវត្ត

ការបង្រៀន និងរៀនវិទ្យាសាស្ត្រតាមបែបរិះរក

មានភាពរលូន និងមានប្រសិទ្ធភាព

**នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ**

ឆ្នាំ ២០១១

# បុព្វកថា

**យោងតាមច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា៦៥ ស្ដីពីវិស័យអប់រំ**

**យោងតាមច្បាប់ស្ដីពីការអប់រំមាត្រា ស្ដីពីការលើកកម្ពស់គុណភាពអប់រំ**

ក្រោមកិច្ចសហការរវាងក្រសួងអប់រំ យុវជន និងកីឡា និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ JICA (STEPSAM2) ដែលមានទិសដៅលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រ នៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និង សាលាគរុកោសល្យនិងវិក្រឹតការ ព្រមទាំងគ្រូវិទ្យា-សាស្ត្រនៅតាមសាលាអនុវិទ្យាល័យអនុវត្ត និងគ្រូវិទ្យាសាស្ត្រនៅសាលាអនុវិទ្យាល័យសហការរបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦។ ក្រុមគ្រូឧទ្ទេសថ្នាក់ជាតិ និងអ្នកជំនាញការអប់រំជប៉ុនបានសហការគ្នាកសាងនិងរៀបរៀងសៀវភៅណែនាំស្ដីពី ការបង្រៀន-រៀនតាមបែបរិះរក ក្នុងបំណងបណ្ដុះការគិតតាមរយៈការសង្កេត ការធ្វើសម្មតិកម្ម ការពិសោធន៍ ការទាញសេចក្ដីសន្និដ្ឋានដល់គរុសិស្ស សិស្សបឋមសិក្សានិងអនុវិទ្យាល័យ តាមរយៈកាបង្រៀនវិទ្យាសាស្ត្រ (គីមីវិទ្យា, ជីវវិទ្យា, រូបវិទ្យា, ផែនដីវិទ្យា) រួមចំណែកសម្រេចគោលដៅអប់រំជាតិប្រកបដោយជោគជ័យ។

ឆ្លងកាត់តាមបទពិសោធន៍របស់គម្រោង STEPSAM2 សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា កន្លងមក ក្រោយពីមានការចុះតាមដាន និងការជួយជាបន្តបន្ទាប់ ចាប់តាំងពីឆ្នាំ ២០០៨ មកឃើញថាសមត្ថភាពគ្រូឧទ្ទេសវិទ្យាសាស្ត្រនៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និង សាលាគរុ-កោសល្យនិងវិក្រឹតការ មានការអភិវឌ្ឍន៍ជាបណ្ដើរៗ ហើយការរៀនរបស់គរុសិស្ស សិស្សសាលាបឋមនិងអនុវិទ្យាល័យមានសញ្ញាណការគិត វិភាគ សំយោគ ធ្វើពិសោធន៍លើមេរៀនវិទ្យាសាស្ត្រ ផ្ទុយពីមុនដែលការបង្រៀនវិទ្យាសាស្ត្រជាលំនាំនៃការបង្រៀន-រៀនអាន ឬរៀនអត្ថបទតែប៉ុណ្ណោះ។

ដើម្បីឲ្យខ្លឹមសារក្នុងសៀវភៅនេះប្រកបដោយប្រសិទ្ធភាព លោកគ្រូ-អ្នកគ្រូវិទ្យាសាស្ត្រទាំងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និង សាលាគរុកោសល្យនិងវិក្រឹតការ ព្រមទាំងសាលាអនុវត្ត គប្បីយកចិត្តទុកដាក់ស្វែងយល់ខ្លឹមសារនេះបានស៊ីជម្រៅ ដើម្បីជាត្រីវិស័យសម្រាប់អនុវត្តសកម្មភាពការបង្រៀន-រៀនតាមបែបរិះរក។

ក្រសួងអប់រំ យុវជន និងកីឡា លោក-លោកស្រី នឹងខិតខំយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពបង្រៀន-រៀនតាមបែបរិះរកប្រកបដោយប្រសិទ្ធភាពនិងភាពស័ក្ដិសិទ្ធិ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

# អារម្ភកថា

សៀវភៅណែនាំស្តីពីការបង្រៀន និងរៀនតាមបែបរិះរកនេះ កើតឡើងដោយសារកិច្ចសហការរវាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ JICA (STEPSAM2) ជាមួយក្រុមគ្រូឧទ្ទេសថ្នាក់ជាតិក្នុងគម្រោង ដោយប្រើប្រាស់ថវិការបស់ JICA (STEPSAM2) ។

ទិសដៅរបស់ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ JICA (STEPSAM2) កែលម្អការបង្រៀននិងរៀន ពិសេសការបង្រៀននិងការរៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និង សាលាគរុកោសល្យ និងវិក្រឹតការ ព្រមទាំងអនុវិទ្យាល័យអនុវត្ត និងអនុវិទ្យាល័យសហការ ក្នុងគោលបំណងកែលម្អទម្លាប់ការបង្រៀនវិទ្យាសាស្ត្រពីមុន មកជាការបង្រៀន និងរៀនវិទ្យាសាស្ត្រតាមបែបរិះរកវិញ។ ដូចនេះគម្រោង STEPSAM2 ដោយមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា បានបើកវគ្គបំប៉នអំពីការបង្រៀន និងរៀនតាមបែបរិះរក ជាបន្តបន្ទាប់ជូនដល់នាយក និងគ្រូឧទ្ទេសវិទ្យាសាស្ត្រ នៅតាមគ្រឹះស្ថានគរុកោសល្យ និងគ្រូវិទ្យាសាស្ត្រ នៅអនុវិទ្យាល័យអនុវត្ត និងអនុវិទ្យាល័យសហការ ដើម្បីឲ្យអាចដំណើរការ ការបង្រៀន និងរៀនតាមបែបរិះរកបានសម្រេច។

ខ្លឹមសារក្នុងសៀវភៅនេះបានលើកឡើងអំពីៈ

- អ្វីទៅជាការបង្រៀន និងរៀនតាមបែបរិះរក
- ដំណើរការបង្រៀន និងរៀនតាមបែបរិះរក
- វាយតម្លៃការបង្រៀន និងរៀនតាមបែបរិះរក
- របៀបអភិវឌ្ឍការបង្រៀន និងរៀនតាមបែបរិះរក
- សំណួរពាក់ព័ន្ធ និងការអភិវឌ្ឍន៍ការបង្រៀន និងរៀនតាមបែបរិះរក

ខ្លឹមសារទាំងអស់បានមកពីការស្រាវជ្រាវពីប្រភពផ្សេងៗ ជាពិសេសបានមកពីការអ្នកជំនាញការជប៉ុន ហើយកែលម្អឲ្យស្របទៅតាមបរិបទអប់រំនៅកម្ពុជា ដើម្បីឲ្យលោកគ្រូ អ្នកគ្រូវិទ្យាសាស្ត្រទាំងអស់ងាយស្រួលអនុវត្តការបង្រៀន និងរៀនប្រកបដោយភាពស័ក្តិសិទ្ធិ។

បន្ទាប់ពីបានបញ្ចូលឯកសារនេះក្នុងវគ្គបំប៉ន និងក្រោយពីបានចុះតាមដានលទ្ធផលនៃការអនុវត្តការបង្រៀន និងរៀនតាមបែបរិះរក គណៈកម្មការនិពន្ធយើងខ្ញុំក៏បានរៀបចំកែសម្រួលខ្លឹមសារឯកសារនេះជាបន្តបន្ទាប់។ ខ្លឹមសារនៅក្នុងសៀវភៅនេះប្រាកដជានៅមានចំណុចខ្វះខាតខ្លះៗដែលគណៈកម្មការនិពន្ធយើងខ្ញុំសូមទទួលស្គាល់ និងរង់ចាំទទួលយកយោបល់កែលម្អអំពីលោក លោកស្រីគ្រប់ពេលវេលា។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដែលបានលើកទឹកចិត្តដល់ក្រុមការងារក្នុងការបង្កើតនូវស្នាដៃនេះ ព្រោះសៀវភៅនេះនឹងក្លាយជាទីប្រឹក្សាដ៏មានប្រសិទ្ធភាពចំពោះលោកគ្រូ អ្នកគ្រូគ្រប់ពេលវេលា។

**ក្រុមការងាររៀបចំឯកសារ**

## គណៈកម្មការនិពន្ធ

១. លោក កូជី តាកាហាស៊ី (Koji TAKAHASHI)

២. លោក ធាន វាសនា

៣. លោក តុង រ៉ូហ្សែត

៤. លោកស្រី អ៊ាង សេងលីម

៥. លោក អ៊ឹម កាណូរ៉ុធ

## គណៈកម្មការពិនិត្យ និងកែលម្អ

១. លោក កូជី តាកាហាស៊ី (Koji TAKAHASHI)

២. លោក សិត សេង

៣. លោក ម៉ម ចាន់សៀន

៤. លោក ង៉ោ ប៉េងឡុង

## គណៈកម្មការរៀបរៀង និងចងក្រង

លោក វិញ សោភ័ណ

# មាតិកា

**មេរៀន** **ទំព័រ**

*មេរៀនទី១៖ តើអ្វីទៅជាការបង្រៀន និងរៀនតាមបែបរិះរក?* ................................. 1

*មេរៀនទី២៖ ប្លង់មេរៀនតាមបែបរិះរក* ............................................................. 4

*មេរៀនទី៣៖ ពីបាតុភូតវិទ្យាសាស្ត្រទៅការរិះរក* ................................................... 7

*មេរៀនទី៤៖ វាយតម្លៃការបង្រៀន និងរៀនតាមបែបរិះរក* .................................. 9

*មេរៀនទី៥៖ របៀបអភិវឌ្ឍការបង្រៀន និងរៀន* ............................................... 12

*មេរៀនទី៦៖ សំណួរដែលត្រូវបានសួរជាញឹកញាប់*........................................... 16

*ឯកសារយោង..........................................................................................20*

# មេរៀនទី១៖ តើអ្វីទៅជាការបង្រៀន និងរៀនតាមបែបរិះរក?

## ១.១. ទិដ្ឋភាពថ្នាក់រៀនវិទ្យាសាស្ត្រ

ជាដំបូងយើងមើលថ្នាក់រៀនវិទ្យាសាស្ត្រដែលកំពុងអនុវត្តក្នុងសាលារៀននៅតាមតំបន់មួយចំនួននៅលើពិភពលោក។ ចូរស្រមៃគិតពីទិដ្ឋភាពថ្នាក់រៀនខាងក្រោម៖

***ទិដ្ឋភាពទី១***

គ្រូអានសៀវភៅឮៗ"តើសត្វជាអ្វី?"នៅក្នុងសៀវភៅវិទ្យាសាស្ត្រ។ សិស្សអង្គុយនៅតាមកន្លែងរបស់ពួកគេដោយស្ងៀមស្ងាត់ ហើយថាតាមពាក្យដែលមាននៅក្នុងសៀវភៅ។ ជួនកាលគ្រូហៅសិស្សមួយចំនួនឲ្យអានសៀវភៅរបស់គេឮៗជំនួសការអានរបស់គាត់។

បន្ទាប់ពីសិស្សអានសៀវភៅហើយ គ្រូចែកសិស្សជាក្រុម ហើយឲ្យសិស្សរកលក្ខណៈ របស់សត្វដែលមាននៅក្នុងសៀវភៅអត្ថបទ។ បន្ទាប់មកសិស្សសរសេរលក្ខណៈរបស់សត្វនៅលើក្រដាសធំ រួចហើយឡើងបង្ហាញតាមក្រុម។

***ទិដ្ឋភាពទី២***

ដំបូងគ្រូប្រាប់សិស្សថាពួកគេនឹងរៀនអំពីគោលការណ៍កម្លាំងឃ្នាស់នៅក្នុងមេរៀនេះ។ រួចគាត់អាចសួរសិស្សថា តើឃ្នាស់ជាអ្វី ហើយគេប្រើប្រាស់នៅទីណា? បន្ទាប់មកគាត់ឲ្យសិស្សបើកសៀវភៅអត្ថបទវិទ្យាសាស្ត្រ ហើយអានពីរបីទំព័រដែលសរសេរអំពី"ឃ្នាស់"។

បន្ទាប់មកទៀតគាត់បង្ហាញពិសោធន៍អំពីគោលការណ៍កម្លាំងឃ្នាស់ ហើយប្រាប់ចម្លើយទៅសិស្សរបស់គាត់។ ជាចុងក្រោយសិស្សសរសេរពីគោលការណ៍កម្លាំងឃ្នាស់នៅក្នុងសៀវភៅសរសេររបស់ពួកគេ។

**តើអ្នកគិតយ៉ាងដូចម្តេចអំពីវិធីសាស្ត្របង្រៀនទាំងពីរខាងលើនេះ? តើវាស្រដៀងគ្នាទៅនឹងវិធីសាស្ត្របង្រៀនរបស់អ្នក ឬទេ? តើសហការីរបស់អ្នកបង្រៀនមេរៀនវិទ្យាសាស្ត្រដូចនោះដែរ ឬទេ?**

## ១.២. មូលដ្ឋានគ្រឹះក្នុងការណែនាំពីវិធីសាស្ត្របង្រៀនតាមមុខវិជ្ជានីមួយៗ

ឥឡូវនេះគ្រូបង្រៀនទាំងអស់នៅលើពិភពលោកបានស្គាល់អំពី "គោលវិធីសិស្សមជ្ឈមណ្ឌល" យ៉ាងហោចណាស់ក៏ស្គាល់ពីឈ្មោះរបស់វាដែរ។ ទោះជាយ៉ាងណាក៏ដោយ នៅមានការយល់ច្រឡំមួយចំនួននៅក្នុងចំណោមគ្រូបង្រៀន។ គ្រូបង្រៀនភាគច្រើនយល់ថា ការបង្រៀនរបស់ពួកគាត់បានអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌលហើយ។ គ្រូមួយចំនួនបាននិយាយថា"ខ្ញុំឲ្យសិស្សធ្វើការជាក្រុមរៀងរាល់ម៉ោងបង្រៀន" ឬ "ខ្ញុំតែងតែសួរសំណួរជាច្រើនទៅសិស្សរបស់ខ្ញុំដើម្បីឲ្យពួកគេមានការគិតច្រើន" ឬ "ខ្ញុំផ្តល់ឱកាសច្រើនដើម្បីធ្វើការអនុវត្ត" ឬ "ខ្ញុំធ្វើពិសោធន៍ជាញឹកញាប់" ។ ប៉ុន្តែតើយើងអាចនិយាយបានថាគោលវិធីបែបនេះសុទ្ធតែជាគោលវិធីសិស្សមជ្ឈមណ្ឌលដែរ ឬទេ?

ដូចលោកគ្រូ អ្នកគ្រូដឹងស្រាប់ហើយថា ចម្លើយពិតណាស់គឺ "ទេ"។ វិធីសាស្ត្រទាំងនោះមិនបានឈានទៅរកការសិក្សាតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលទេ។ ជាឧទាហរណ៍ ដូចដែលយើងបានឃើញជារឿយៗមកហើយដូចជា៖

- (ចំពោះការធ្វើការជាក្រុម) មានសិស្សតែពីរបីនាក់ប៉ុណ្ណោះដែលបានគិត និងជួយ ហើយសិស្សដទៃទៀតបានតែអង្គុយមើលដោយមិនបានជួយអ្វីទាំងអស់។ ឬមួយក៏គ្រូដាក់សំណួរឲ្យសិស្សទៅតាមក្រុមនីមួយៗ ហើយមានសិស្សពូកែម្នាក់ ឬពីរនាក់ប៉ុណ្ណោះជាអ្នកឆ្លើយទៅនឹងសំណួរនេះ។
- (ចំពោះការធ្វើពិសោធន៍) គ្រូជាអ្នកធ្វើពិសោធន៍ ក៏ប៉ុន្តែ (១) វាមិនបានផ្ដល់ឲ្យសិស្សនូវចំណេះដឹង និងជំនាញថ្មីៗទាក់ទងផ្នែកវិទ្យាសាស្ត្រទេ (២) លទ្ធផលដែលទទួលបាន វាមិនបានសម្រេចគោលបំណងនៃមេរៀនទេ (៣) ការសន្និដ្ឋានរបស់សិស្សបានមកពីការរកឃើញនៅក្នុងសៀវភៅពុម្ពដែលមិនមែនបានមកពីលទ្ធផលពីការធ្វើពិសោធន៍ទេ។

នៅក្នុងករណីខាងលើនេះ ដំណើរការនៃការបង្រៀន-រៀនគឺវាស្ថិតនៅឆ្ងាយពីគោលវិធីសិស្សមជ្ឈមណ្ឌល។

ដូច្នេះ តើអ្នកគិតថាមានអ្វីដែលនាំឲ្យមានការសន្និដ្ឋានបែបនេះ? គំនិតភាគច្រើនគិតថា គោលវិធីសិស្សមជ្ឈមណ្ឌលដែលផ្ដោតទៅលើការអប់រំវិទ្យាសាស្ត្រ គណិតវិទ្យា ភាសា និងសិក្សាសង្គម ពុំទាន់បានណែនាំឲ្យបានល្អិតល្អន់ដល់គ្រូបង្រៀនទាក់ទងនឹងគោលវិធីសិស្សមជ្ឈមណ្ឌលនៅឡើយទេ។

<u>"ការរិះរក" ជាវិធីមួយនៅក្នុងវិធីសាស្ត្រសិស្សមជ្ឈមណ្ឌលដែលផ្ដោតទៅលើការអប់រំវិទ្យាសាស្ត្រ។</u> ការណែនាំអំពីគោលវិធីនេះ ផ្ដល់ឲ្យគ្រូបង្រៀនមេរៀនវិទ្យាសាស្ត្រនូវទិដ្ឋភាពច្បាស់លាស់មួយនៃ"ការបង្រៀន និងរៀនមេរៀនវិទ្យាសាស្ត្រតាមគោលវិធីសិស្សមជ្ឈមណ្ឌល"។

## ១.៣. តើអ្វីជាការបង្រៀន និងរៀនតាមបែបរិះរក?

"ការរិះរក" មានន័យថា "ការរកចំណេះដឹងតាមរយៈសំណួរ"។ ដូច្នេះការបង្រៀន និងរៀនតាមបែបរិះរក គឺជាការបង្រៀនដែលលើកទឹកចិត្តសិស្សឲ្យធ្វើការជាមួយគ្នា ដើម្បីផ្ដល់ចម្លើយទៅនឹងសំណួររបស់ពួកគាត់ ជាជាងការបង្រៀនដោយផ្ទាល់ពីគ្រូ ធ្វើអ្វីៗតាមគ្រូ។ ការងាររបស់គ្រូនៅក្នុងការបង្រៀន និងរៀនតាមបែបរិះរក គឺមិនមែនផ្ដល់ចំណេះដឹងទៅឲ្យសិស្សនោះទេ ប៉ុន្តែត្រូវជួយសិស្សឲ្យរកបាននូវចំណេះដឹងដោយខ្លួនគេ។

ការបង្រៀន និងរៀនតាមបែបរិះរក តម្រូវឲ្យសិស្សសង្កេត និងវិភាគអំពីបាតុភូតវិទ្យាសាស្ត្រ ដើម្បីបង្កើតសំណួរ ធ្វើពិសោធន៍ដើម្បីឆ្លើយទៅនឹងសំណួររបស់ពួកគេ និងទាញសេចក្ដីសន្និដ្ឋានសមស្របតាមរយៈលទ្ធផលពិសោធន៍។ នៅក្នុងដំណើរការនេះ សិស្សនឹងយល់ពីខ្លឹមសារបានស៊ីជម្រៅ ទទួលបានជំនាញ និងចំណេះដឹងបែបវិទ្យាសាស្ត្រពិតប្រាកដ។

នៅពេលដែលសិស្សរៀនវិទ្យាសាស្ត្រនៅក្នុងថ្នាក់តាមបែបរិះរកពួកគេក្លាយជា "អ្នកវិទ្យាសាស្ត្រពាក់កណ្ដាល" ទៅហើយ ពីព្រោះពួកគេប្រើប្រាស់វិធីសាស្ត្រដូចគ្នានឹងអ្នកវិទ្យាសាស្ត្រប្រើនៅពេលធ្វើការស្រាវជ្រាវដែរ។ ដំណើរការដែលសិស្សត្រូវធ្វើនៅក្នុងការបង្រៀន និងរៀនតាមបែបរិះរកគឺបង្ហាញដូចនៅក្នុងរូបទី១នៅទំព័របន្ទាប់។




**រូបទី១ ដំណើរការនៃការបង្រៀន និងរៀនតាមបែបរិះរក**

នៅក្នុងការបង្រៀន និងរៀនតាមបែបរិះរក គ្រូបង្រៀនក៏អាចទទួលបានផងដែរនូវបទពិសោធអំពីការសិក្សាវិទ្យាសាស្ត្រតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល បើទោះបីជាវិធីសាស្ត្រនៃការបង្រៀន-រៀនតាមបែបរិះរកទាមទារឲ្យគ្រូបង្រៀនត្រូវមានចំណេះដឹងខ្ពស់ខាងផ្នែកវិទ្យាសាស្ត្រ ហើយនិងជំនាញក្នុងការបង្រៀនខ្ពស់ជាងវិធីសាស្ត្រធម្មតាក្ដី។

*សំណួរ និងការពិភាក្សាទី១* — *ឆ្លើយជាបុគ្គលរួចហើយពិភាក្សាជាមួយសមាជិកក្នុងក្រុមរបស់អ្នក*

*១-១) តើលោកគ្រូ អ្នកគ្រូបានសិក្សាមេរៀនវិទ្យាសាស្ត្រយ៉ាងដូចម្ដេចនៅសាលាបឋមសិក្សា និងមធ្យមសិក្សា? ចូរប្រៀបធៀបពីវិធីសាស្ត្រដែលលោកគ្រូ អ្នកគ្រូធ្លាប់បានរៀន ជាមួយនឹងវិធីសាស្ត្របង្រៀន-រៀនតាមបែបរិះរក ។*

*១-២) ចូរបញ្ជាក់គុណសម្បត្តិ និងគុណវិបត្តិដែលអាចកើតមានឡើង ចំពោះការណែនាំអំពីវិធីសាស្ត្របង្រៀន-រៀនតាមបែបរិះរកនៅក្នុងសាលា។*

# មេរៀនទី២៖ ប្លង់មេរៀនតាមបែបរិះរក

## ២.១. សមាសភាគក្នុងការបង្រៀន និងរៀនតាមបែបរិះរក

ដូចជាការបង្រៀននៅក្នុងថ្នាក់ធម្មតាដែរ ការបង្រៀន និងរៀនតាមបែបរិះរកមានវត្ថុបំណងមេរៀន និងសកម្មភាពដែលបម្រើឲ្យវត្ថុបំណងនោះ។ តារាងទី២ ខាងក្រោមបង្ហាញពីទំនាក់ទំនងរវាងសមាសភាគនៃការបង្រៀន និងរៀនវិទ្យាសាស្ត្រតាមបែបរិះរក ដែលរួមមាន "ទំនាក់ទំនងវត្ថុបំណងមេរៀន" "ការបង្ហាញបាតុភូត" "សំណួរគន្លឹះ" "ការស្រាវជ្រាវ" និង "ការសន្និដ្ឋាន"។

## ២.២. សំណួរគន្លឹះ

លក្ខណៈសំខាន់បំផុតដែលធ្វើឲ្យការបង្រៀន និងរៀនតាមបែបរិះរក ខុសពីកាបង្រៀន និងរៀនតាមបែបផ្សេងៗទៀតគឺ "សំណួរគន្លឹះ" ឬ"សំណួរចាំបាច់" ដែលមានតួនាទីជាសំខាន់ នៅក្នុងការបង្រៀន និងរៀន។

ដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម "សំណួរគន្លឹះ" ត្រូវបានបង្កើតឡើងផ្អែកតាមការសង្កេតនិងការពិភាក្សារបស់សិស្សទៅលើបាតុភូតវិទ្យាសាស្ត្រ ដែលគ្រូបានផ្តល់ឲ្យ។ បន្ទាប់មកសិស្សត្រូវពិភាក្សា និងបង្កើតសម្មតិកម្ម ដោយមានហេតុផលច្បាស់លាស់ ដើម្បីរៀបចំសកម្មភាព ប្រមូលទិន្នន័យ សម្រាប់ទាញសេចក្តីសន្និដ្ឋានមួយដែលឆ្លើយតបទៅនឹងវត្ថុបំណងនៃមេរៀន។




រូបទី២ ទំនាក់ទំនងរវាងសមាសភាគមេរៀន

## ២.៣. ការស្រាវជ្រាវនៅក្នុងការបង្រៀន និងរៀនតាមបែបរិះរក

"ការស្រាវជ្រាវ" រួមមាន ការពិសោធ ការសង្កេត និងការវិភាគ គួររៀបចំឲ្យបានល្អដើម្បីឆ្លើយតបទៅនឹង "សំណួរគន្លឹះ" និងដើម្បីទាញនូវ "សេចក្តីសន្និដ្ឋាន" ដូចដែលបានរំពឹងទុក។ ជារឿយៗកំហុសតែងតែកើតមានចំពោះគ្រូដែលទើបចាប់ផ្តើមបង្រៀនដោយប្រើវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកគឺ៖

- ការរៀបចំពិសោធន៍ ដែលមិនសូវទាក់ទងទៅនឹងសំណួរគន្លឹះ ឬវត្ថុបំណងមេរៀន
- ការធ្វើពិសោធន៍ដើម្បីបញ្ជាក់ចម្លើយដែលសិស្សបានដឹងរួចមកហើយ
- ការយកចិត្តទុកដាក់តិចតួចទៅនឹងលទ្ធផលរបស់សិស្សដែលខុសឆ្ងាយទៅនឹងលទ្ធផលដែលរំពឹងទុក និងចំណុចផ្សេងៗទៀត។

បញ្ហាដែលកើតមានទាំងអស់ខាងលើបណ្តាលមកពីគ្រូមានបទពិសោធតិចតួច ចំណេះដឹងខាងមុខវិជ្ជាឯកទេសខ្សោយ វិធីសាស្ត្របង្រៀននៅមានកម្រិត និងលំដាប់លំដោយពិសោធន៍មិនច្បាស់លាស់។ ដូចនេះដើម្បីអនុវត្តនូវការបង្រៀន និងរៀនតាមបែបរិះរកបានល្អទាមទារឲ្យគ្រូសិក្សាស្រាវជ្រាវឲ្យបានច្រើនអំពីខ្លឹមសារដែលត្រូវបង្រៀន។

## ២.៤. សេចក្តីសន្និដ្ឋានលើការបង្រៀន និងរៀនតាមបែបរិះរក

យើងត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់លើ "ការសន្និដ្ឋាន" ចំពោះការបង្រៀន និងរៀនតាមបែបរិះរក។ គួររំឭកថា គ្រូមិនត្រូវធ្វើសេចក្តីសន្និដ្ឋាននោះទេ ក៏ប៉ុន្តែសិស្សទៅវិញទេដែលត្រូវទាញសេចក្តីសន្និដ្ឋានដោយផ្អែកលើសកម្មភាពស្រាវជ្រាវ និងលទ្ធផលពិសោធន៍របស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ចំពោះបញ្ហានេះលទ្ធផលពិសោធន៍មួយចំនួនពិតជានឹងមានកំហុស ឬល្អៀងខ្លះៗដែលនាំឲ្យមានការសន្និដ្ឋានខុសពីការរំពឹងទុកជាក់ជាមិនខាន។ ភាគច្រើននៃលទ្ធផលទាំងនោះបណ្តាលមកពីជំនាញនៃការវាស់វែងរបស់សិស្សពុំបានត្រឹមត្រូវ និងមួយចំនួនទៀតគឺកំហុសដែលមិនអាចជៀសផុត ដែលតែងតែកើតមាននៅក្នុងពិសោធន៍។ គ្រូត្រូវតែពិនិត្យរាល់ដំណើរការទាំងអស់នៅក្នុងពិសោធន៍ ហើយជួយសិស្សឲ្យធ្វើបានត្រឹមត្រូវ។ ប្រសិនបើមានការសន្និដ្ឋានផ្សេងៗគ្នាក្នុងចំណោមក្រុមសិស្សផ្សេងៗគ្នា នោះគ្រូត្រូវតែសម្រេចចិត្តថាតើពួកគេត្រូវបន្តការពិភាក្សាតទៅទៀត ឬសម្របសម្រួលឲ្យពួកគេទាញសេចក្តីសន្និដ្ឋានដែលសិស្សភាគច្រើននៅក្នុងថ្នាក់អាចទទួលយកបាន (ប៉ុន្តែមិនត្រូវបង្ខំនោះទេ) ឬក៏បង្រៀនមេរៀនមួយផ្សេងទៀតដើម្បីបញ្ជាក់ថាការ សន្និដ្ឋានណាមួយត្រឹមត្រូវអាចទទួលយកបាន។

ម្យ៉ាងវិញទៀត វាហាក់បីដូចជាគ្រូវិទ្យាសាស្ត្រភាគច្រើនមានការច្រឡំរវាង "ការសន្និដ្ឋាន" និង "លទ្ធផលពិសោធន៍"។ តែការពិតគឺវាខុសគ្នាទាំងស្រុង។ ដូចដែលមានបង្ហាញនៅក្នុងតារាងទី២ លទ្ធផលពិសោធន៍ គឺមានន័យថាជាព័ត៌មានដែលទទួលបានក្រោយពីការធ្វើពិសោធន៍។ សន្និដ្ឋានបានមកពីវិភាគទៅលើលទ្ធផលពិសោធន៍ វាមិនត្រឹមតែបានផ្តល់ចម្លើយចំពោះសំណួរគន្លឹះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានឆ្លើយតបទៅនិងវត្ថុបំណងនៃមេរៀនទៀតផង។

**សំណួរ និងការពិភាក្សាទី២** ឆ្លើយជាបុគ្គលរួចហើយពិភាក្សាជាមួយសមាជិកក្នុងក្រុមរបស់អ្នក

២-១) ចូរបញ្ជាក់និងពិភាក្សាពីភាពខុសគ្នារវាងលំនាំនៃការបង្រៀន និងរៀនតាមបែបរិះរក និងមេរៀនវិទ្យាសាស្ត្រដែលយើងបានសង្កេតជារឿយៗ។

២-២) ចូរឲ្យឧទាហរណ៍ដើម្បីញែកឲ្យដាច់រវាង "សេចក្តីសន្និដ្ឋាន" និង "លទ្ធផលពិសោធន៍" នៅក្នុងមេរៀនវិទ្យាសាស្ត្រ។

# មេរៀនទី៣៖ ពីបាតុភូតវិទ្យាសាស្ត្រទៅការរិះរក

## ៣.១. "សំណួរគន្លឹះ" និង "ការបង្ហាញពីបាតុភូត"

"ការបង្ហាញពីបាតុភូត" ឬភាសាជប៉ុនហៅថា "Jishou-Teiji" គឺជាសកម្មភាពតូចមួយធ្វើនៅដើមមេរៀនដែលគ្រូតម្រង់ការយកចិត្តទុកដាក់របស់សិស្សទៅលើខ្លឹមសារនៃមេរៀន ហើយជួយឲ្យពួកគេបង្កើតនូវ "សំណួរគន្លឹះ" បាន។

ជាទូទៅ "ការបង្ហាញពីបាតុភូត" ចាប់ផ្តើមឡើងចេញពីការសង្កេតបាតុភូតធម្មជាតិ ព្រឹត្តិការណ៍ជាយថាហេតុ រូបភាព ឬវីដេអូដែលទាក់ទាញ។ល។ ដំណើរការនេះបន្តដោយការពិភាក្សារបស់សិស្សតាមរយៈការផ្តើមសំណួរដោយ "ហេតុអ្វី" ឬ"មានអ្វីប្រសិនបើ" ឬអ្វីមួយដែលជំរុញ ការគិតរបស់សិស្ស។ ឆ្លងតាមរយៈសកម្មភាពទាំងនេះ គ្រូចាប់ផ្តើមបង្រួមទំហំការគិតរបស់សិស្សឲ្យតូចទៅៗ ដើម្បីផ្តោតលើសំណួរគន្លឹះរបស់មេរៀន។

ចូរចំណាំថា "ការបង្ហាញពីបាតុភូត" មិនចាំបាច់ធ្វើឡើងគ្រប់មេរៀនទេ វាអាចលុបចោលបានប្រសិនបើមេរៀនថ្ងៃនេះទាក់ទងផ្ទាល់ទៅនឹងមេរៀននៅម៉ោងមុន។

## ៣.២. ឧទាហរណ៍ពី"ការបង្ហាញបាតុភូត" ឆ្ពោះទៅ"សំណួរគន្លឹះ"

ឧទាហរណ៍ខាងក្រោមនឹងជួយឲ្យលោកគ្រូ អ្នកគ្រូយល់ពីរបៀបបង្ហាញបាតុភូត និងការបង្រួមការពិភាក្សាឆ្ពោះទៅរកសំណួរគន្លឹះ។

*ឧទាហរណ៍ទី១៖ បាតុភូតរូប*

បង្ហាញកញ្ចក់ទៅសិស្ស ហើយឲ្យពួកគេនិយាយពីរបៀបប្រើវា។ សួរសិស្សថាតើវត្ថុអ្វីដែលពួកគេអាចមើល និងវត្ថុអ្វីដែលពួកគេមិនអាចមើលឃើញនៅក្នុងកញ្ចក់ ហើយឲ្យពួកគេលេងកញ្ចក់ពីបីនាទី។ បង្កើតសំណួរគន្លឹះថា តើកញ្ចក់បង្កើតកាំពន្លឺយ៉ាងដូចម្តេច? លើកទឹកចិត្តសិស្សឲ្យនិយាយពីការទស្សន៍ទាយដោយសេរីទៅនឹងសំណួរ ហើយចាប់ផ្តើម ធ្វើពិសោធន៍តាមក្រុម។

*ឧទាហរណ៍ទី២៖ ព្រឹត្តិការណ៍កើតឡើងដោយយថាហេតុ*

ដុតក្រដាសនឹងភ្លើងទៀន ហើយឲ្យសិស្សពិនិត្យមើលក្រដាសកំពុងឆេះ។ រួចហើយ ដាក់ទឹកចូលក្នុងប៉ោងប៉ោង យកទៀនដុតវា ហើយឲ្យសិស្សធ្វើការទស្សន៍ទាយថាមានអ្វី កើតឡើងប្រសិនបើដាក់បាតប៉ោងប៉ោងដែលមានដាក់ទឹកឲ្យប៉ះនឹងអណ្តាតភ្លើង។ បន្ទាប់មក ឲ្យសិស្សពន្យល់ហេតុផលអំពីការទស្សន៍ទាយរបស់គេ។ បន្ទាប់ពីការបង្ហាញរបស់សិស្ស គ្រូបង្ហាញពីលទ្ធផលនៃការដុតបាតប៉ោងប៉ោងដែលមានដាក់ទឹកមិនផ្ទុះ ដែលធ្វើឲ្យសិស្ស បង្កើតសំណួរថាហេតុអ្វីបានជាវាមិនផ្ទុះ?។

*ឧទាហរណ៍ទី៣៖ ការប្រើរូបភាព*

សួរសិស្សថាតើពួកគេធ្លាប់ឃើញនៅពេលថ្ងៃមេឃស្រឡះគ្មានពពក ស្រាប់តែព្រះអាទិត្យបាត់មួយរយៈពេលខ្លី រួចស្រាប់តែឃើញមានមកវិញ ឬទេ។ បន្ទាប់មកបង្ហាញរូបភាពអំពីសូរ្យគ្រាស រួចដឹកនាំការ

ពិភាក្សាដោយសេរីអំពីបាតុភូតនេះ។ ឧទាហរណ៍ តើពួកគេខ្លាចសូរ្យគ្រាសឬទេ? តើពួកគេធ្លាប់ឮរឿងផ្សេងៗទាក់ទងនឹងសូរ្យគ្រាសឬទេ?។ល។ បន្តិចម្តងៗទាញអារម្មណ៍សិស្សឲ្យផ្តោតទៅលើសំណួរ «ហេតុអ្វីបានជាមានសូរ្យគ្រាសកើតឡើង?» ដែលជាសំណួរគន្លឹះរបស់មេរៀន។

## ៣.៣. របៀបបង្កើត «សំណួរគន្លឹះ»

សំណួរគន្លឹះនៅក្នុងការបង្រៀន និងរៀនតាមបែបរិះរកគឺវាមានទំនាក់ទំនងយ៉ាងជិតស្និតទៅនឹងវត្ថុបំណងនៃមេរៀន។ ម្យ៉ាងទៀត សំណួរគន្លឹះគួរតែត្រូវបានបង្កើតឡើងយ៉ាងណាដើម្បីឲ្យសិស្សអាចសម្រេចបាននូវវត្ថុបំណងមេរៀន តាមរយៈការឆ្លើយសំណួរគន្លឹះនេះ។

ឧទាហរណ៍ប្រសិនបើវត្ថុបំណងមេរៀនជា៖

*«សិស្សនឹងអាចពន្យល់បានពីខួបរបស់ប៉ោលទោលអាស្រ័យនឹងប្រវែងខ្សែ»*

នោះសំណួរគន្លឹះអាចជា៖

*«ដើម្បីធ្វើការផ្លាស់ប្តូរខួបនៃលំយោលរបស់ប៉ោលទោល តើយើងត្រូវធ្វើយ៉ាងដូចម្តេច?»*

ក្នុងមេរៀននេះ សិស្សនឹងធ្វើពិសោធន៍ដើម្បីរកកត្តាទាំងឡាយដែលមានឥទ្ធិពលលើខួបរបស់ប៉ោលទោល ដោយប្រើប៉ោលដែលមានម៉ាស និងប្រវែងខ្សែខុសៗគ្នា។

វាកាន់តែប្រសើរ ប្រសិនបើសិស្សអាចបង្កើតសំណួរគន្លឹះបែបនេះដោយខ្លួនឯងក្នុងពេលរៀនពីព្រោះពួកគេកាន់តែមានឆន្ទៈចង់ដោះស្រាយបញ្ហា ឬរកឲ្យឃើញនូវចម្លើយរបស់សំណួរគន្លឹះនោះ ប្រសិនបើសំណួរនោះសួរចេញពីពួកគេផ្ទាល់។ ដូច្នេះ គ្រូបង្រៀនត្រូវតែគិតពីរបៀបនាំសិស្សឲ្យទៅដល់សំណួរគន្លឹះដូចជាតាមរយៈការបង្ហាញពីបាតុភូតវិទ្យាសាស្ត្រទាក់ទងនឹងជីវភាពប្រចាំថ្ងៃរបស់សិស្ស ហើយដែលសិស្សនឹងត្រូវធ្វើការបកស្រាយនៅជំហានបន្ទាប់។

| *សំណួរ និងការពិភាក្សាទី៣* | *ឆ្លើយជាបុគ្គលរួចហើយពិភាក្សាជាមួយសមាជិកក្នុងក្រុមរបស់អ្នក* |
|---|---|

*៣-១)* *ចូរដាក់វត្ថុបំណងនៃមេរៀនមួយចំនួន និងរៀបចំសំណួរគន្លឹះដែលទាក់ទងជាមួយវត្ថុបំណងទាំងនេះ។*

*៣-២)* *យោងទៅតាមឧទាហរណ៍ដែលបានរៀបរាប់នៅក្នុងចំណុច ៣.២. ខាងលើ ចូររកឧទាហរណ៍ផ្សេងទៀតអំពី "ការបង្ហាញបាតុភូត" ដែលឈានទៅរកសំណួរគន្លឹះដែលបានរៀបចំនៅក្នុងសំណួរ ៣.១. ខាងលើ។*

# មេរៀនទី៤៖ វាយតម្លៃការបង្រៀន និងរៀនតាមបែបរិះរក

## ៤.១. តើគោលបំណងរបស់យើងគឺអ្វី?

គ្រូបង្រៀនជាច្រើនបានសួរសំណួរដូចជា៖

*តើគ្រូបង្រៀនចាំបាច់ត្រូវមានចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងចំណេះដឹងផ្នែកការរិះរកកម្រិតណា ដើម្បីអាចបង្រៀនមេរៀនវិទ្យាសាស្ត្រតាមបែបរិះរកបាន?*

ជាការពិតណាស់ មានចំណេះដឹងបែបនេះកាន់តែច្រើនកាន់តែប្រសើរ។ ប្រសិនបើគ្រូបង្រៀនមានចំណេះដឹងច្រើនអំពីការរិះរក និងចំណេះដឹងលើមុខវិជ្ជាវិទ្យាសាស្ត្រនោះការបង្រៀន-រៀនតាមបែបរិះរករបស់គាត់នឹងរិតតែមានប្រសិទ្ធភាព។ ដូច្នេះ គ្រូបង្រៀនត្រូវបានលើកទឹកចិត្តឲ្យរៀន និងស្រាវជ្រាវបន្ថែមគ្រប់ពេលវេលា មិនត្រឹមតែតាមរយៈវគ្គបំប៉នប៉ុណ្ណោះទេ ប៉ុន្តែក៏តាមរយៈគ្រូបង្រៀនដទៃទៀត ដែលជាសហការី ព្រមទាំងសិស្សផងដែរ។ ***ការគិតថាខ្លួនល្អគ្រប់គ្រាន់ហើយ វាគឺជាសត្រូវនឹងការធ្វើឲ្យប្រសើរឡើង។***

ម្យ៉ាងទៀត គ្រូបង្រៀនដែលផ្តោតទៅលើកម្រិតនៃការរិះរក តែងតែសួរសំណួរដូចជា៖

*តើសិស្សត្រូវធ្វើការរិះរកកម្រិតណា ក្នុងមេរៀនតាមបែបរិះរក?*

មិនមានចម្លើយច្បាស់លាស់សម្រាប់សំណួរនេះទេ ហើយថែមទាំងមានការយល់ច្រឡំមួយចំនួនក្នុងចំណោមគ្រូបង្រៀន ដូចជាថា «មេរៀនរបស់ខ្ញុំ និងមេរៀនរបស់គាត់មានកម្រិតការិះរកខុសគ្នា ប៉ុន្តែតើយើងអាចហៅមេរៀនទាំងពីនេះថាជា មេរៀនតាមបែបរិះរកដែរ ឬទេ?» ។ល។

វាត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយថា ពិតជាមានកម្រិតនៃការរិះរកច្រើនមែន។ ខណៈពេលដែលអ្នកនិពន្ធខុសគ្នាបានផ្តល់នូវគំនិតខុសៗគ្នា ក្នុងឯកសារនេះយើងសូមលើកយកការលើកឡើងរបស់លោក Fay & Bretz (2008)ស្តីពីកម្រិតនៃការិះរកនេះ, ពីព្រោះវាហាក់ដូចជាងាយយល់ និងអាចអនុវត្តបាននៅក្នុងប្រទេសកម្ពុជា។

## ៤.២. កម្រិតនៃការរិះរក

លោក Fay & Bretz (2008) បានស្នើឡើងនូវកម្រិតនៃការរិះរកដូចមានក្នុងតារាងទី១ដែលផ្តោតទៅលើបីចំណុចទាក់ទងនឹងសកម្មភាពមន្ទីរពិសោធន៍ដូចជា៖

- បញ្ហា ឬសំណួរដែលសិស្សត្រូវធ្វើការដោះស្រាយ
- ដំណើរការ ឬវិធីសាស្ត្រដែលសិស្សត្រូវប្រើសម្រាប់ធ្វើការសង្កេត
- ចម្លើយ ឬសេចក្តីសន្និដ្ឋានដែលសិស្សត្រូវបង្កើតឡើងនៅទីបញ្ចប់។

តារាងទី២ ផ្តល់នូវសេចក្តីលម្អិតអំពីកម្រិតនៃការរិះរកនីមួយៗ។

**តារាងទី១ កម្រិតនៃការរិះរក**

| កម្រិត | បញ្ហា ឬសំណួរគន្លឹះ | ដំណើរការ ឬវិធីសាស្រ្ត | សេចក្តីសន្និដ្ឋាន |
|---|---|---|---|
| **0** | ផ្តល់ឲ្យសិស្ស | ផ្តល់ឲ្យសិស្ស | ផ្តល់ឲ្យសិស្ស |
| **1** | ផ្តល់ឲ្យសិស្ស | ផ្តល់ឲ្យសិស្ស | បង្កើតឡើងដោយសិស្ស |
| **2** | ផ្តល់ឲ្យសិស្ស | បង្កើតឡើងដោយសិស្ស | បង្កើតឡើងដោយសិស្ស |
| **3** | បង្កើតឡើងដោយសិស្ស | បង្កើតឡើងដោយសិស្ស | បង្កើតឡើងដោយសិស្ស |

ប្រភព: Fay &Bretz (2008)

**តារាងទី២ សេចក្តីលម្អិតនៃកម្រិតរិះរកនីមួយៗ**

| កម្រិត | សេចក្តីលម្អិត (លក្ខណៈសម្គាល់នៃកម្រិតនីមួយៗគឺបង្ហាញដោយអក្សរដិត) |
|---|---|
| **0** | *សំណួរគន្លឹះ ដំណើរការ* និង*សេចក្តីសន្និដ្ឋាន*ត្រូវបាន **ផ្តល់ឲ្យសិស្ស**។ សិស្សធ្វើពិសោធន៍ និងផ្ទៀងផ្ទាត់ចម្លើយជាមួយនឹងសៀវភៅសិក្សា។ |
| **1** | *សំណួរគន្លឹះ* និង*ដំណើរការ* ត្រូវបាន **ផ្តល់ឲ្យសិស្ស**។ សិស្សពន្យល់ បកស្រាយទិន្នន័យពិសោធន៍ និងផ្តល់*សេចក្តីសន្និដ្ឋាន* ដែលសមហេតុផល។ |
| **2** | *សំណួរគន្លឹះ* ត្រូវបាន **ផ្តល់ឲ្យសិស្ស**។ សិស្ស**ត្រូវគិត និងរៀបចំដំណើរការ**ដើម្បីធ្វើការសង្កេត **កំណត់ទិន្នន័យដែលត្រូវវាស់វែង** និងបកស្រាយ ទិន្នន័យពិសោធន៍ និងផ្តល់*សេចក្តីសន្និដ្ឋាន* ដែលសមហេតុផល។ |
| **3** | បាតុភូតមួយត្រូវបានផ្តល់ឲ្យសិស្ស។ សិស្ស **ធ្វើការបង្កើត** (ឬសំយោគ) បញ្ហា ឬសំណួរគន្លឹះមួយ រួចសិស្សត្រូវគិត និងរៀបចំដំណើរការដើម្បីធ្វើការសង្កេត កំណត់ទិន្នន័យដែលត្រូវវាស់វែង និងបកស្រាយ ទិន្នន័យពិសោធន៍ និងផ្តល់*សេចក្តីសន្និដ្ឋាន* ដែលសមហេតុផល។ |

ប្រភព: Fay &Bretz (2008)

ដូចដែលបានឃើញនូវក្នុងតារាងខាងលើ សេរីភាព និងការទទួលខុសត្រូវរបស់សិស្សមានការកើនឡើងពីកម្រិត 0 ទៅ 3។ នៅកម្រិត 3 ត្រូវបានគេចាត់ទុកថាជាកម្រិតល្អបំផុតនៃការរិះរក ដូច្នេះ អ្នកអាចវាយតម្លៃការបង្រៀន និងរៀនរបស់អ្នកថាតើវាស្ថិតនៅក្នុងម្រិត 1 ហើយឬនៅ? សូមចងចាំថានៅកម្រិត 0 មានន័យថា «គ្មានការរិះរក» ទេ។

ទោះបីជាមិនអាចរៀបចំជាការបង្រៀន និងរៀនដោយតាមបែបរិះរកបានសម្រាប់គ្រប់មេរៀនវិទ្យាសាស្រ្តទាំងអស់ក៏ដោយ តារាងខាងលើអាចផ្តល់ជាគំនិត និងគោលដៅដែលអាចសាកល្បងបាន អាស្រ័យទៅលើការខិតខំប្រឹងប្រែងរបស់គ្រូបង្រៀន និងស្ថានភាពជាក់ស្តែង (កម្រិតយល់ដឹង) របស់សិស្ស ព្រមទាំងបរិស្ថានសម្ភាររបស់សាលាផងដែរ។ ប្រសិនបើការបង្រៀន និងរៀនរបស់អ្នកជាធម្មតាស្ថិតនៅកម្រិត 0 ជាដំបូងអ្នកអាចសាកល្បងបន្តទៅកម្រិត 1 ឬកម្រិត 2។ តែប្រសិនបើមេរៀនរបស់អ្នកបានទៅដល់កម្រិត 3 ហើយនោះអ្នកត្រូវបន្តធ្វើការកែលម្អគុណភាព ឬប្រសិទ្ធភាពរបស់សកម្មភាពនីមួយៗ បន្ថែមទៀត។ ការកែលម្អ គឺគ្មានទីបញ្ចប់ឡើយ។

| សំណួរ និងការពិភាក្សាទី៤ | ឆ្លើយជាបុគ្គលរួចហើយពិភាក្សាជាមួយសមាជិកក្នុងក្រុមរបស់អ្នក |
|---|---|

៤-១) ចូរបញ្ជាក់ពីមេរៀនវិទ្យាសាស្ត្ររបស់ខ្លួនឯងដោយប្រើតារាងទី ១។ តើមេរៀនវិទ្យាសាស្ត្ររបស់លោកគ្រូ/អ្នកគ្រូស្ថិតនៅក្នុងកម្រិតប៉ុន្មាន?

៤-២) តើលោកគ្រូ/អ្នកគ្រូអាចធ្វើដូចម្ដេចដើម្បីឲ្យមេរៀនវិទ្យាសាស្ត្ររបស់លោកគ្រូ/អ្នកគ្រូកាន់តែមានកម្រិតនៃរិះរកខ្ពស់ថែមទៀត? តាមទស្សនៈយល់ឃើញខាងលើ ចូរពិភាក្សាដើម្បីរកចន្លោះប្រហោងដើម្បីធ្វើការកែលម្អ "បញ្ហា/សំណួរគន្លឹះ" "លំនាំ/វិធីសាស្ត្រ" ហើយនិង "ដំណោះស្រាយ"។

# មេរៀនទី៥៖ របៀបអភិវឌ្ឍការបង្រៀន និងរៀន

## ៥.១. ប្រការយល់ដឹងមុនពេលធ្វើកិច្ចតែងការបង្រៀន

នៅក្នុងមេរៀនដោយតាមបែបរិះរក សំខាន់បំផុតត្រូវជួយសិស្សឲ្យអាចបង្កើតសំណួរ ឬចម្ងល់នៅក្នុងចិត្តរបស់គេបាន តាមរយៈការបង្ហាញបាតុភូតធម្មជាតិទាក់ទងនឹងជីវភាពប្រចាំថ្ងៃរបស់ពួកគេ ជាជាងប្រាប់ពួកគេអំពីវត្ថុបំណងមេរៀនដោយផ្ទាល់។

បន្ទាប់ពីការកំណត់បញ្ហា (សំណួរគន្លឹះ) រួចហើយ គ្រូត្រូវធ្វើការសម្របសម្រួលឲ្យសិស្សធ្វើការពិភាក្សាគ្នាអំពីអ្វីដែលពួកគេត្រូវធ្វើការអង្កេត និងថាតើពួកគេត្រូវធ្វើដូចម្ដេចខ្លះ? នៅទីនេះ តួនាទីរបស់គ្រូគឺត្រូវបង្កើតបរិយាកាសមួយដែលនាំឲ្យសិស្សអាចចែករំលែកមតិយោបល់រវាងគ្នានឹងគ្នាដោយសេរី–និងយ៉ាងសកម្ម។ គ្រូបង្រៀនមិនត្រូវជ្រៀតជ្រែក ឬរំខានការពិភាក្សារបស់សិស្សឡើយ ប៉ុន្តែត្រូវជួយជំរុញការគិតរបស់សិស្សដូចជាការបំផុសគំនិតផ្ទុយទៅនឹងគំនិតសិស្ស ឬការផ្ដល់គំនិតខុសទាំងស្រុងជាដើម។ ប្រសិនបើការពិភាក្សារបស់សិស្សត្រូវបានកាច់ចង្កូតដោយគ្រូ នោះសិស្សនឹងពុំអាចយល់បានច្បាស់លាស់ទេ ថាតើហេតុអ្វីបានជាពួកគេត្រូវធ្វើដូច្នោះនៅពេលគេធ្វើពិសោធន៍ ហើយវានឹងនាំទៅដល់ភាពបរាជ័យក្នុងការសម្រេចនូវវត្ថុបំណងមេរៀន។

## ៥.២. ដំណើរការអភិវឌ្ឍកិច្ចតែងការបង្រៀនតាមបែបរិះរក

ក្នុងការអភិវឌ្ឍកិច្ចតែងការបង្រៀនមួយ លំនាំ «ធ្វើផែនការបញ្ច្រាស់» ត្រូវបានគេប្រើជាញឹកញាប់។ តាមរបៀបនេះ គ្រូបង្រៀនត្រូវធ្វើការពិចារណាអំពីដំណើរមេរៀនតាមលំដាប់លំដោយ ចាប់ផ្ដើមពី៖ **វត្ថុបំណងមេរៀន → សេចក្ដីសន្និដ្ឋាន → សកម្មភាព/ពិសោធន៍ → សំណួរគន្លឹះ → ការបង្ហាញបាតុភូត**។ វិធីសាស្ត្រនេះអាចជួយឲ្យគ្រូបង្រៀនបន្តផ្ដោតអារម្មណ៍ទៅលើវត្ថុបំណងរបស់មេរៀន។

### *១. ការកំណត់វត្ថុបំណងមេរៀន*

• ដំបូង គ្រូបង្រៀនត្រូវតែយល់អំពីវត្ថុបំណងរបស់មេរៀន ឬជំពូក។ បន្ទាប់មកគាត់ត្រូវធ្វើការពិចារណាអំពីចំណេះដឹង និងជំនាញដែលសិស្សគួរទទួលបានតាមរយៈមេរៀននីមួយៗ។ សូមចងចាំថាការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាពកាលណាវត្ថុបំណងមេរៀន ដែលបានកំណត់ឡើងមានទំនាក់ទំនងទៅនឹងមេរៀនមុន និងមេរៀនដែលត្រូវរៀនបន្ទាប់។ ប្រសិនបើវត្ថុបំណងមេរៀននីមួយៗត្រូវបានកំណត់ដាច់ៗពីគ្នា (គ្មានទំនាក់ទំនងគ្នា) នោះឱកាសនៃការសិក្សាតាមដានបន្តរបស់សិស្សនឹងត្រូវបាត់បង់។

### *២. ការកំណត់សេចក្ដីសន្និដ្ឋាន និងសកម្មភាព*

• ដោយផ្អែកទៅលើវត្ថុបំណងមេរៀនដែលបានកំណត់ខាងលើ គ្រូបង្រៀនត្រូវគិតថា តើសិស្សនឹងធ្វើសកម្មភាពអ្វី និងយ៉ាងដូចម្ដេច នៅក្នុងដំណើរការសិក្សារបស់គេ។ ឧទាហរណ៍ ប្រសិនបើវត្ថុបំណងមេរៀនជា «សិស្សនឹងអាចពន្យល់បានអំពីទំនាក់ទំនងរវាងមុំចាំងផ្លាត និងមុំចាំងប៉ះ» នោះសិស្សនឹងត្រូវ

ធ្វើការវាស់វែងមុំទាំងនោះ ដោយប្រើឧបករណ៍ដូចជាបន្ទាត់រ៉ាប៉័រទ័រ ខ្មៅដៃ ពន្លឺពិល កញ្ចក់ជាដើម ដើម្បីរកឲ្យឃើញការពិតដែលថា មុំទាំងពីរនេះតែងតែស្មើគ្នាជានិច្ច។

*៣. ការកំណត់សំណួរគន្លឹះ*

• បន្ទាប់មកទៀត គ្រូបង្រៀនត្រូវតែគិតអំពីថាតើសំណួរគន្លឹះអ្វីដែលគួរបង្កើតឡើង ដើម្បីឲ្យសិស្សអាចចាប់ផ្តើមសកម្មភាពដូចរៀបរាប់ខាងលើ។ សំណួរនេះត្រូវធ្វើយ៉ាងណាឲ្យច្បាស់ និងងាយយល់បំផុត។ ឧទាហរណ៍ ករណីមុំចាំងប៉ះ និងមុំចាំងផ្លាតខាងលើ សំណួរគន្លឹះអាចជា «តើមុំចាំងប៉ះ និងមុំចាំងផ្លាតមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច?» ឬ «តើកាំពន្លឺធ្វើដំណើរយ៉ាងដូចម្តេច នៅពេលវាប៉ះលើកញ្ចក់?»

*៤. ការកំណត់ពីបាតុភូតផ្សេងៗដែលត្រូវបង្ហាញ*

• នៅដំណាក់កាលចុងក្រោយ គ្រូបង្រៀនត្រូវគិតអំពីវិធីដ៏មានប្រសិទ្ធភាពបំបផុត ដើម្បីជួយសិស្សឲ្យអាចបង្កើតចម្ងល់ ឬសំណួរគន្លឹះក្នុងចិត្តរបស់គេ។ ចូរព្យាយាមរកនឹកមើលរាល់បាតុភូតនៅជុំវិញខ្លួនយើង រកមើលសៀវភៅវិទ្យាសាស្ត្រផ្សេងៗ និងស្វែងរកបាតុភូតធម្មជាតិ (រូប ឬគីមី) ឬហេតុការណ៍ផ្សេងៗ ឬរូបភាពគួរឲ្យចាប់ចាប់អារម្មណ៍ដើម្បីជួយជំរុញការគិតរបស់សិស្សឲ្យកាន់តែស៊ីជម្រៅ។ ក្នុងឧទាហរណ៍នៃមុំចាំងប៉ះ និងមុំចាំងផ្លាតខាងលើ មេរៀនអាចចាប់ផ្តើមតាមរយៈឲ្យសិស្សសង្កេតបាតុភូតធម្មជាតិមួយអំពីការចាំងផ្លាតនៃពន្លឺ ឬការលេងពិល និងកញ្ចក់ជាដើម។

## ៥.៣. កិច្ចតែងការបង្រៀនគំរូ

កិច្ចតែងការបង្រៀនខាងក្រោមជាគំរូមួយស្តីអំពីការរៀបចំសកម្មភាពបង្រៀន និងរៀនលើមេរៀន «ចំណាំងផ្លាតនៃពន្លឺ» សម្រាប់សិស្សអនុវិទ្យាល័យ ដោយប្រើការបង្រៀន និងរៀនតាមបែបរិះរក។

| |
|---|
| **ប្រធានបទ៖** ដំណាលនៃពន្លឺ<br>**វត្ថុបំណង៖** ក្រោយពីបញ្ចប់មេរៀននេះសិស្សអាច៖<br>• ពន្យល់ពីទំនាក់ទំនងរវាងមុំចាំងប៉ះ និងមុំចាំងផ្លាត។<br>• អាចវាស់បាននូវមុំចាំងប៉ះ និងមុំចាំងផ្លាតតាមរយៈការធ្វើពិសោធន៍។<br>• មានបម្រុងប្រយ័ត្នក្នុងការប្រើពិលឡាសែ និងកញ្ចក់ពេលធ្វើពិសោធន៍។ |

**កិច្ចតែងការបង្រៀន (សង្ខេបគំរូ)**

| **សកម្មភាពគ្រូ** | **ខ្លឹមសារ** | **សកម្មភាពសិស្ស** |
|---|---|---|
| សួរសិស្ស តើកាំពន្លឺដាលយ៉ាងដូចម្តេច? ប្រើពិល និងទៀនដើម្បីធ្វើឲ្យសិស្សនឹកឃើញពិសោធន៍នៅក្នុងមេរៀនមុន។<br><br>ទុកពេលឲ្យសិស្សគិត តើយើងអាចចាំងពន្លឺទៅលើវត្ថុមួយដោយប្រើពិលបានយ៉ាងដូចម្តេច នៅពេលដែលមានឧបសគ្គនៅចន្លោះរវាងពិល និងវត្ថុ? | រំលឹកមេរៀនចាស់ (៥ នាទី)<br><br>បង្ហាញពីបាតុភូត (១០ នាទី) | សិស្សនឹកឃើញពីរបៀបដាលនៃពន្លឺ។ ចម្លើយពួកគេមានៈ..................<br><br>សិស្សគិតអំពីរបៀបចាំងពន្លឺទៅលើវត្ថុមួយ នៅពេលដែលកាំពន្លឺមិនអាចប៉ះនឹងវត្ថុដោយផ្ទាល់។ សិស្សនឹងអាចគិតឃើញថា គេអាចប្រើកញ្ចក់ដើម្បីធ្វើវា។ |
| ***សំណួរៈ** តើកាំពន្លឺដាលយ៉ាងដូចម្តេច នៅពេលវាត្រូវបានចាំងផ្លាតពីកញ្ចក់មួយ?* | | |
| ប្រើរូប (បង្ហាញខាងស្តាំ)ដើម្បីសម្របសម្រួលសិស្សក្នុងការទស្សន៍ទាយលទ្ធផល ពិសោធន៍ សួរថា តើពន្លឺចាំងទៅទិសណាបន្ទាប់ពីវាចាំងផ្លាតពីកញ្ចក់? តើបាច់នៃពន្លឺចាំងផ្លាតមានចលនាយ៉ាងដូចម្តេច ប្រសិនបើពិលមានចលនាទៅឆ្វេង ឬទៅស្តាំ? |  | សិស្សគិតអំពីសំនួរខាងលើដោយប្រើរូបភាពដែលបានបង្ហាញ។ បន្ទាប់មកពួកគេនឹងទស្សន៍ ពីលទ្ធផល។ |
| ធ្វើឲ្យសិស្សស្គាល់ ពីអ្វីជាមុំចាំងប៉ះ និងអ្វីជាមុំចាំងផ្លាត។ | ធ្វើពិសោធន៍ (២០ នាទី) | សិស្សសិក្សាពីនិយ័តភាពរបស់ ចំណាំងផ្លាតនៃពន្លឺ។ |
| **ចូរវាស់មុំចាំងផ្លាតដែលត្រូវនឹងមុំចាំងប៉ះខុសៗគ្នា!** | | |
| ទុកពេលឲ្យសិស្សគិតពីរបៀបវាស់មុំទាំងនោះ។<br>សង្កេតមើលតើសិស្សចេះប្រើប្រាស់រ៉ាប់ព័រទ័របានត្រឹមត្រូវដែរឬទេ។ | | ដំបូងសិស្សគូសមុំចាំងប៉ះ និងមុំចាំងផ្លាតនៃកាំពន្លឺលើក្រដាស ដោយប្រើប៊ិច និងបន្ទាត់ បន្ទាប់មកវាស់មុំទាំងនោះនៅលើក្រដាស ដោយប្រើរ៉ាប់ព័រទ័រ។ |

| | | |
|---|---|---|
| ឲ្យសិស្សគូសក្រាបតាមលទ្ធផលដែលទទួលបាន។ | ពិភាក្សា (១០ នាទី) | សិស្សពិភាក្សា ហើយសរុបលទ្ធផលពិសោធន៍។ |
| (សង្ខេប)<br>**មុំចំណាំងផ្លាតពីកញ្ចក់នៃកាំពន្លឺស្មើមុំចំណាំងប៉ះ** | | |
| ត្រូវប្រាកដថាសិស្សទាំងអស់បានរកឃើញនិយ័តភាពនៃចំណាំងផ្លាត | | |
| ដាក់លំហាត់ឲ្យសិស្សអំពីចំណាំងផ្លាតនៃពន្លឺមួយចំនួន។ | អនុវត្ត(៥ នាទី) | សិស្សដោះស្រាយបញ្ហា។ |

*សំណួរ និងការពិភាក្សាទី៥* *ឆ្លើយជាបុគ្គលរួចហើយពិភាក្សាជាមួយសមាជិកក្នុងក្រុមរបស់អ្នក*

*៥-១) ចូរសរសេរកិច្ចតែងការតាមបែបរិះរកម្នាក់មួយ។*

*៥-២) ចូរពិភាក្សាកិច្ចតែងការជាក្រុម ហើយកែលម្អវាឲ្យរឹតតែមានលក្ខណៈរិះរកថែមទៀត តាមរយៈការសហការគ្នា។*

# មេរៀនទី៦៖ សំណួរចម្លើយពាក់ព័ន្ធការបង្រៀន-រៀនតាមបែបរិះរក

## ៦.១. សំណួរទូទៅទាក់ទងនឹងការបង្រៀន និងរៀនតាមបែបរិះរក

*សំណួរ:* តើគ្រូគួរតែជំរុញសិស្ស ឲ្យស្វែងរកចម្លើយដើម្បីឆ្លើយនឹងសំណួររបស់គ្រូតាមរយៈការស្រាវជ្រាវ ឬការពិសោធដោយខ្លួនឯងជានិច្ចឬទេ?

*ចម្លើយ:*វាមិនមែនជានិច្ចកាលអញ្ចឹងទេ។ វាអាស្រ័យនឹងវត្ថុបំណងរបស់មេរៀន។ ឧទាហរណ៍ សិស្សអាចចោទជាសំណួរថា តើមានចំណុចរំពុះប៉ុន្មាននៅកម្រិតកម្ពស់ទឹកសមុទ្រ ប្រសិនបើវាជាអ្វី ដែលនឹងត្រូវរៀនក្នុងមេរៀននេះ សិស្សត្រូវការបង្កើតនូវការអង្កេតដើម្បីស្វែងរកនូវចម្លើយនោះ។ ប្រសិនជាចម្លើយនៃសំណួរនោះជាការបកស្រាយបញ្ហាដែលមានក្នុងមេរៀន ឬប្រសិនបើវត្ថុបំណងរបស់មេរៀននេះត្រូវប្រើសម្ភារៈឧបទេសជំនួយ នោះគ្រូអាចប្រាប់សិស្សឲ្យរកមើលព័ត៌មាននៅក្នុងសៀវភៅនាខណៈពេលនោះ។ ប្រសិនបើមានឱកាសច្រើនសម្រាប់ឲ្យសិស្សគិតគូរ ពុំចាំបាច់ឲ្យសិស្សបើកសៀវភៅមើលទេ។

*សំណួរ:* តើអ្វីដែលសំខាន់ជាងគេសម្រាប់សិស្ស ដើម្បីបង្កើនសមត្ថភាពរិះគិតបែបវិទ្យាសាស្ត្រ ឬខ្លឹមសារ និងគោលការណ៍សំខាន់ៗនៃវិទ្យាសាស្ត្រ?

*ចម្លើយ:*លទ្ធផលនៃការសិក្សាទាំងនេះមានសារៈសំខាន់ស្មើគ្នាគឺថាវាផ្ដល់ឲ្យគ្នាទៅវិញទៅមក។ នៅក្នុងដំណើរការនៃការបង្រៀន និងរៀនជាច្រើន សិស្សត្រូវប្រើសមត្ថភាពការរិះរក ដើម្បីអភិវឌ្ឍការយល់ដឹងខ្លឹមសារវិទ្យាសាស្ត្ររបស់គេ។

*សំណួរ:* តើការបង្រៀន និងរៀនតាមបែបរិះរកជាវិធីសាស្ត្របង្រៀនដ៏ល្អបំផុតឬទេ?

*ចម្លើយ:*ទោះបីជា ការបង្រៀន និងរៀនតាមបែបរិះរកជាវិធីសាស្ត្របង្រៀនចាំបាច់មួយ សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ ប៉ុន្តែវិធីសាស្ត្របង្រៀនផ្សេងទៀតជាច្រើនក៏អាចធ្វើឲ្យសម្រេចគោលបំណង នៃការរៀនវិទ្យាសាស្ត្រផងដែរ។ វាអាចកើតឡើងផងដែរ ដោយគ្រាន់តែការអានសៀវភៅវិទ្យាសាស្ត្រ ឬក៏ការធ្វើសកម្មភាពដោយគ្មានការរិះគិត ឬក៏គ្រាន់តែចងចាំនូវចំណេះដឹងវិទ្យាសាស្ត្រ ក៏អាចធ្វើឲ្យលទ្ធផលនៃការសិក្សាបានប្រសើរជាងការបង្រៀន និងរៀនតាមបែបរិះរកផងដែរ។ និយាយរួមវាអាស្រ័យនឹងវត្ថុបំណងមេរៀន។

*សំណួរ:* តើគ្រូបង្រៀនគួរប្រើវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកគ្រប់មេរៀនវិទ្យាសាស្ត្រទាំងអស់ដែរឬទេ ?

***ចម្លើយ:*** ទេ ដូចដែលបានឆ្លើយខាងលើរួចហើយ ការបង្រៀន និងរៀនតាមបែបរិះរកមិនមែនជាវិធីសាស្ត្រតែមួយគត់សម្រាប់រៀនវិទ្យាសាស្ត្រនោះទេ។ ឧទាហរណ៍ គ្រូមិនអាចប្រើវិធីសាស្ត្ររិះរកសម្រាប់គ្រប់មេរៀនវិទ្យាសាស្ត្រទេ ម្យ៉ាងគឺពុំមានពេលគ្រប់គ្រាន់ដោយសារម៉ោងបង្រៀនតិច ព្រោះការបង្រៀន និងរៀនតាមបែបរិះរកត្រូវការពេលវេលាគ្រប់គ្រាន់។ ក្នុងករណីនេះ គ្រូគួរប្រើយុទ្ធសាស្ត្រផ្សេងទៀតដើម្បីអភិវឌ្ឍចំណេះដឹង និងសមត្ថភាពរបស់សិស្ស។ លើសពីនេះទៅទៀត កម្រិតនៃការរិះរកដែលសិស្សអាចធ្វើបាន គឺប្រែប្រួលអាស្រ័យលើខ្លឹមសារមេរៀន មុខវិជ្ជា កម្រិតយល់ដឹង និងជំនាញជាក់ស្តែងរបស់សិស្ស។

***សំណួរ:*** តើការបង្រៀន និងរៀនតាមបែបរិះរក និងវិធីវិទ្យាសាស្ត្រខុសគ្នាយ៉ាងដូចម្តេច?

***ចម្លើយ:***វិធីវិទ្យាសាស្ត្រជាវិធីសាស្ត្រមួយ ដែលអ្នកវិទ្យាសាស្ត្រយកមកប្រើ ដើម្បីសួរ និងឆ្លើយនូវសំណួរវិទ្យាសាស្ត្រដោយធ្វើការសង្កេត និងធ្វើពិសោធន៍។ ការបង្រៀន និងរៀនតាមបែបរិះរកគឺជាយុទ្ធវិធីបង្រៀនដោយផ្អែកលើវិធីវិទ្យាសាស្ត្រ។ នៅពេលដែលអ្នកវិទ្យាសាស្ត្រប្រើវិធីវិទ្យាសាស្ត្រ ពួកគេត្រូវការប្រើពេលវេលាច្រើន ដើម្បីធ្វើការនៅក្នុងទីពិសោធន៍ យ៉ាងហោចណាស់រាប់សប្តាហ៍ ដើម្បីធ្វើការអង្កេត និងរៀបចំឯកសារ។ ម្យ៉ាងវិញទៀត វិធីវិទ្យាសាស្ត្រនៅក្នុងការបង្រៀន និងរៀនតាមបែបរិះរកមានតួនាទីយ៉ាងសំខាន់ក្នុងការជួយជំរុញការរៀនរបស់សិស្ស និងជួយឲ្យសម្រេចបាននូវវត្ថុបំណងរបស់មេរៀន។ នៅក្នុងមេរៀនមួយ សិស្សមិនចាំបាច់ត្រូវតែរកឲ្យឃើញនូវព្រឹត្តិការណ៍វិទ្យាសាស្ត្រថ្មីទាំងស្រុង ដូចអ្នកវិទ្យាសាស្ត្រនោះទេ។ ជាងនេះទៅទៀត កម្មវិធីសិក្សារបស់សាលាក្នុងមួយឆ្នាំសិក្សាតម្រូវឲ្យគ្រូ និងសិស្សអនុវត្តដំណើការបែបការរិះរក ដែលជាធម្មតាឲ្យបានមួយមេរៀន (៤០ ទៅ ៥០ នាទី) ឬក៏ពីរមេរៀនយ៉ាងច្រើន។

***សំណួរ:*** តើការរៀបចំការបង្រៀន និងរៀនតាមបែបរិះរកត្រូវការពេលវេលាច្រើនជាងការបង្រៀន និងរៀនតាមបែបធម្មតាឬ ?

***ចម្លើយ:***មែនហើយ វាត្រូវប្រើប្រាស់ពេលវេលាជាច្រើនម៉ោង ឬច្រើនថ្ងៃ ដើម្បីរៀបចំសម្រាប់មេរៀនមួយ ដូចជាគ្រូត្រូវធ្វើការប៉ាន់ស្មាននូវសំណួរសិស្ស ការគិតជាមុនយ៉ាងហ្មត់ចត់អំពីរបៀបឆ្លើយនូវសំណួរទាំងនោះ ការបង្កើតសំណួរគន្លឹះដែលអាចទាក់ទាញសិស្សក្នុងពេលបង្រៀន និងរៀនអភិវឌ្ឍដំណើរការសង្កេត រៀបចំសម្ភារឧបទ្ទេសបង្រៀន និងឧបករណ៍សម្រាប់ធ្វើពិសោធន៍ជាដើម។ បន្ទាប់មកទៀត ការរៀនតាមបែបរិះរក សិស្សត្រូវចំណាយពេលយ៉ាងច្រើន ដើម្បីទទួលបាននូវចំណែកមួយនៃចំណេះដឹងវិទ្យាសាស្ត្រ។ សិស្សត្រូវជំរុញឲ្យបង្កើតសំណួរគន្លឹះ ដោយមានការជួយណែនាំពីគ្រូរៀបចំរបៀបសង្កេត ការធ្វើតេស្តលទ្ធផលពិសោធន៍ និងការទាញសេចក្តីសន្និដ្ឋាន ដើម្បីឆ្លើយទៅនឹងសំណួរគន្លឹះ។ វាត្រូវចំណាយពេលអស់ច្រើនជាងមួយម៉ោងទៅទៀត ឆ្លងតាម រយៈដំណើរការនេះ រហូតដល់សិស្សមានទំលាប់ធ្វើការរិះរក បើទោះបីជាវាអាចបញ្ចប់ក្នុងរយៈពេលតែប៉ុន្មាននាទីតាមរយៈគ្រូប្រាប់ចម្លើយ ឬក៏សិស្សមើលសៀវភៅសិក្សាក៏ដោយ។

ទោះជាយ៉ាងណាក៏ដោយជួនកាលវាត្រូវចំណាយពេលខ្លីដែរ។ ឧទាហរណ៍ កម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា ចំណាយពេល ៣ ម៉ោងសម្រាប់បញ្ញតិមួយ ដែលមានរួមបញ្ចូលនូវខ្លឹមសារវិទ្យាសាស្ត្រសំខាន់ៗ និងព័ត៌មានផ្សេងៗជាច្រើនទៀតដែលទាក់ទងនឹងវិទ្យាសាស្ត្រ។ ដូចនេះ វាអាចកាត់បន្ថយម៉ោងបង្រៀន ដោយបង្កើតនូវមេរៀន បង្រៀន និងរៀនតាមបែបរិះរកមួយដើម្បីសិក្សាខ្លឹមសារមេរៀននោះ ហើយឲ្យសិស្សអានផ្នែកដែលនៅសល់ក្នុងសៀវភៅសិក្សា។ ក្នុងករណីនេះ វត្ថុបំណងមេរៀនអាចសម្រេចបានដោយប្រើរយៈខ្លី ហើយសិស្សអាចយល់បានច្បាស់នូវវត្ថុបំណងមេរៀននោះទៀតផង។

*សំណួរ:* តើជំហាននៅក្នុងការបង្រៀន និងរៀនតាមបែបរិះរក និងជំហានទាំងប្រាំនៅក្នុងកិច្ចតែងការបង្រៀនមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច ?

***ចម្លើយ:***កិច្ចតែងការបង្រៀននៅកម្ពុជាមានប្រាំជំហាន ត្រួតពិនិត្យថ្នាក់ រំឭកមេរៀនចាស់ ការសិក្សាមេរៀនសម្រាប់ថ្ងៃនេះ ពង្រឹងពុទ្ធិ និងកិច្ចការផ្ទះ។ ជំហាននៅក្នុងការបង្រៀន និងរៀនតាមបែបរិះរកគឺច្រើនតែស្ថិតនៅក្នុងជំហានទី៣(ការសិក្សាមេរៀនសម្រាប់ថ្ងៃនេះ)។ ដូចនេះ គ្រូបង្រៀនអាចរក្សាការប្រើជំហានទាំងប្រាំរបស់កិច្ចតែងការបង្រៀន ដោយមិនចាំបាច់ផ្លាស់ប្តូរទេ។

## ៦.២. សំណួរស្តីអំពីបច្ចេកទេស

*សំណួរ:* តើបង្រៀនមេរៀនមួយតាមបែបរិះរកយ៉ាងដូចម្តេច ប្រសិនបើវាគ្រាន់តែបញ្ជាក់នូវចម្លើយដែលមាននៅក្នុងសៀវភៅសិក្សា ឬក៏សិស្សអាចរកឃើញចម្លើយត្រឹមត្រូវបាននៅក្នុងសៀវភៅសិក្សា?

***ចម្លើយ:***អ្នកក៏អាចសួរផងដែរថា ប្រសិនបើគ្រូបង្រៀនម្នាក់បង្រៀនមេរៀនមួយដោយប្រើវិធីបង្រៀន និងរៀនតាមបែបរិះរក តើគ្រូអាចអនុញ្ញាតឲ្យសិស្សអានសៀវភៅសិក្សាដែរឬទេ? ចម្លើយគឺវាអាស្រ័យទៅលើខ្លឹមសារ ហើយនឹងគ្រូដែលជាអ្នកបង្រៀន។ ប្រសិនបើសៀវភៅសិក្សា មានផ្តល់នូវព្រឹត្តិការណ៍វិទ្យាសាស្ត្រងាយៗ ដូចនេះ ការបង្រៀន និងរៀនតាមបែបរិះរករបស់អ្នក អាចចាប់ផ្តើមដោយសំណួរគន្លឹះ (ដែលមិនមានទាំងស្រុងនៅក្នុងសៀវភៅសិក្សា) ជំរុញឲ្យសិស្សគិតយ៉ាងហ្មត់ចត់ ដើម្បីអាចរកឲ្យឃើញនូវព្រឹត្តិការណ៍នោះ ហើយធ្វើដូចម្តេចដើម្បីធ្វើពិសោធន៍បាន។ លទ្ធផលពិសោធន៍អាចមានការខុសគ្នាតិចតួច ឬច្រើនពីទ្រឹស្តីដែលមាននៅក្នុងសៀវភៅសិក្សា។ ស្ថានភាពបែបនេះបានផ្តល់ឱកាសយ៉ាងច្រើនសម្រាប់ការរិះគិតរបស់សិស្ស ហើយគ្រូអាចណែនាំសិស្សឲ្យស្វែងរកឲ្យឃើញនូវកត្តាដែលបណ្តាលឲ្យមានភាពលម្អៀងនោះ។ ក្នុងករណីដូចខាងលើ វាមិនមែនជាបញ្ហាដែលថាសិស្សអានសៀវភៅសិក្សាមុន ឬក៏អត់នោះទេ។

*សំណួរ:* នៅក្នុងការបង្រៀន និងរៀនតាមបែបរិះរក តើយើងមិនត្រូវបង្ហាញវត្ថុបំណងមេរៀនដល់សិស្សជាមុនទេឬ?

***ចម្លើយ:***ទេអ្នកមិនត្រូវបង្ហាញវត្ថុបំណងមេរៀនឲ្យច្បាស់លាស់ដល់សិស្សនោះទេ បើទោះបីជាគ្រូបង្រៀនត្រូវតែយល់វត្ថុបំណងឲ្យបានច្បាស់ និងរៀបរាប់វានៅក្នុងកិច្ចតែងការបង្រៀនក៏ដោយ។ ឧទាហរណ៍ ប្រសិនជាយើងប្រាប់សិស្ស (វត្ថុបំណងមេរៀននេះគឺដើម្បីធ្វើចំណាត់ថ្នាក់សត្វ) នៅពេលចាប់ផ្តើមមេរៀន ពេលនោះពួកគេគិតថា វាដូចជាគេបង្ខំឲ្យធ្វើអ្វីមួយដោយគ្រូ ឬដោយសាលា វាមិនមែនជាអ្វីដែលការចង់ដឹងចង់ឃើញ ឬក៏ជាចំណាប់អារម្មណ៍របស់ពួកគេឡើយ។ ដូចដែលបានពន្យល់ខាងដើម ការបង្ហាញនូវបាតុភូតដើរតួជាគន្លឹះ ដើម្បីជំរុញពួកគេឲ្យបង្កើតសំណួរគន្លឹះ ហើយដើម្បីសម្រេចវត្ថុបំណងមេរៀនបានតាមរយៈធ្វើសកម្មភាព។

## ឯកសារយោង

### ឯកសារសិក្សា


Fay, M. E. and Bretz, S. L. (2008).Structuring the level of inquiry in your classroom: A rubric helps teachers compare experiments and plan inquiry trajectories, *The Science Teacher*, Vol. 75, No. 5. (2008),38-42.

Hassard, J. and **Dias, M. (2008).*The Art of Teaching Science.*** *Inquiry and Innovation in Middle School and High School, 2nd Edition*.New York, Routledge


### ឯកសារសំខាន់ៗជាភាសាខ្មែរ


STEPSAM2 (2009). Resource book 1 for science trainers/directors of TTCs
STEPSAM2 (2010). Resource book 2 for science trainers/directors of TTCs


### គេហទំព័រស្តីអំពីការបង្រៀន និងរៀតដោយតាមបែបរិះរក


Educational Development Center.(2001). **An Introduction to Inquiry-based Learning**. Youth Learn.http://www.youthlearn.org/learning/approach/inquiry.asp

Collier, C., Johnson, J., Nyberg, L., & Lockwood, V. Frequently Asked Questions about Inquiry**. Learning Science Through Inquiry**. Annenberg Media.http://www.learner.org/channel/workshops/inquiry/resources/faq.html

Center for Science, Mathematics, and Engineering.**Inquiry and the National Education Standard**s.National Research Council.http://books.nap.edu/html/inquiry_addendum/index.html

Educational Broadcasting Corporation. (2004). **Concept to Classroom: Inquiry-based Learning**.http://www.thirteen.org/edonline/concept2class/inquiry/index.html

ឧបត្ថម្ភ និងបោះពុម្ពដោយ

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

និងគម្រោង STEPSAM2